

# ការនិយាយជាមួយកូនលោកអ្នក

ការប្រើវិធីសាស្ត្រទាំងនេះ អាចជួយកូនលោកអ្នកក្នុងការ
បណ្តុះជំនាញភាសា។

**បែរមុខឲ្យចំ** កូនរបស់លោកអ្នក ហើយសម្រុតខ្លួនឲ្យស្មើនឹងកូន លគឺអង្គុយនៅលើកម្រាលក្តារ/ឥដ្ឋ/ព្រំ ឬ តុ។

**អង្កេតមើល** ហើយយកចិត្តទុកដាក់ទៅនឹងចំណាប់អារម្មណ៍របស់កូន។
ចូលរួមលេងជាមួយអ្វីដែលកូនកំពុងលេង ឬកំពុងនិយាយ។

**រង់ចាំឲ្យ** កូនលោកអ្នកធ្វើឬនិយាយអ្វីមុនសិន (សូរសំឡេង, ពាក្យ ឬសកម្មភាព) ។ បន្ទាប់មក ឆ្លើយឬធ្វើតបទៅវិញ។

**ធ្វើតាម** នូវអ្វីដែលកូនធ្វើ ហើយរង់ចាំឲ្យកូនរៀនធ្វើតាមលោកអ្នក។
លោកអ្នកអាចធ្វើតាមសូរសំឡេងរបស់កូន(ឧ. "ប្រឹមៗ!"), ពាក្យ (ឧ. "សំឡេងទឹកជះសាច") ឬសកម្មភាព (ឧ. ការលោតចុះឡើង)។

**ផ្តល់ឲ្យ** កូនលោកអ្នកនូវពាក្យអ្វីមួយសម្រាប់ផ្គូផ្គងទៅនឹងអ្វីដែលកូនកំពុងរិះគិតរកមើល, កំពុងធ្វើ ឬកំពុងសួរ។ ឧ. "កូនកំពុងលោតបានខ្ពស់ដល់ហើយ!" ឬ "ទឹកដោះគោថែមទៀតឬ?"

**ប្រើ** ពាក្យពេចន៍ខុសៗគ្នាជាច្រើន មានដូចជាឈ្មោះរបស់/វត្ថុ (ឧ. "បាល់"), សកម្មភាព (ឧ. "បោះមក!") ព្រមទាំងពាក្យសម្រាប់ការពិពណ៌នា (ឧ. "ធំ" និង "ធ្ងន់")។ លោកអ្នកអាចនិយាយពាក្យទាំងនោះម្តងហើយម្តងទៀត ដើម្បីជួយឲ្យកូនរៀនពាក្យទាំងនោះ។

**បន្ថែម** ពាក្យមួយម៉ាត់ឬច្រើនថែមទៀតទៅលើអ្វីដែលកូនលោកអ្នកបាននិយាយ។ ឧ. កូនក្មេង៖ "ផសៗ"; មនុស្សពេញវ័យ៖ "អុញនោះ ពពុះនោះផ្ទុះផស!" ។

**បង្ហាញ** កូនលោកអ្នកនូវអ្វី ដែលលោកអ្នកកំពុងនិយាយ។ ឧ. នៅពេលចូលទៅក្នុងឡាន សូមបង្ហាញឲ្យកូនឃើញនូវកូនសោ ដោយនិយាយថា "យើងកំពុងតែចូលទៅក្នុងឡានហើយ"។

Stronger Families and Communities Strategy
An Australian Government Initiative

learning links
Helping Kids Learn

THE SMITH FAMILY
everyone's family

*Communities for Children is supported by the Australian Government under the Stronger Families & Communities Strategy*